ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

សារលិខិតរំលែកទុក្ខ
របស់ថ្នាក់ដឹកនាំ និងភរិយា មន្ត្រីរាជការ
នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ខ្ញុំ និងភរិយា ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានក្តីក្តុកក្តួលរន្ធត់ចិត្តឥតឧបមាដោយបានទទួលព័ត៌មានថា **ឯកឧត្តម សាយ ភូថង ជាសមាជិកគណៈអចិន្ត្រៃយ៍គណបក្សប្រជាជនកម្ពុជា** បានទទួលមរណភាពកាលពីវេលាម៉ោង ០៥:០៦ នាទីល្ងាច ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ ក្នុងជន្មាយុ ៩៦ ឆ្នាំ ដោយរោគាពាធ ។

ក្នុងឱកាសប្រកបដោយក្តីខ្សឹកខ្សួលរំជួលចិត្ត ក្រៀមក្រំស្ងើរកទីបំផុតគ្មាននេះ ខ្ញុំ និងភរិយា ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈសូមសម្តែងនូវសមានទុក្ខប្រកបដោយអនិច្ចលក្ខណធម៌ដ៏មហាជ្រាលជ្រៅ ព្រមទាំងក្តីសង្វេគដ៏មហាធំធេង និងពោពេញដោយក្តីសោកស្តាយស្រណោះអាឡោះអាល័យជាអនេកប្បការចំពោះ **ឯកឧត្តម សាយ ភូថង** ដែលបានលាចាកលោក លាចាកពីកូនចៅ ចៅទួត ព្រមទាំងលាចាកពីយើងខ្ញុំទាំងអស់គ្នា។

ការបាត់បង់វត្តមានដ៏ឧត្តុងឧត្តមនៃ **ឯកឧត្តម សាយ ភូថង** នាឱកាសនេះគឺជាការបាត់បង់នូវវីរៈជនដ៏ឆ្នើមរបស់ជាតិ និងជាថ្នាក់ដឹកនាំមួយរូបបានបំពេញកិច្ចស្នេហាជាតិ ដើម្បីរួមចំណែកក្នុងសុខសន្តិភាព និងការអភិវឌ្ឍន៍សម្រាប់ជាតិខ្មែរប្រកបដោយបញ្ញាញាណភ្លឺថ្លាវៀងវៃគ្រប់កាលៈទេសៈ។ ថ្វីបើរូបកាយរបស់ **ឯកឧត្តម សាយ ភូថង** ទម្លាយក្ខន្ធទៅកាន់បរលោកហើយក្តី ប៉ុន្តែលំអានវីរៈជនគំរូដ៏ឆ្នើមរបស់ **ឯកឧត្តម សាយ ភូថង** ស្ថិតជានិច្ចក្នុងមនសិការរបស់ខ្ញុំបាទ និងភរិយា ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជនរួមជាតិនឹងស្ថិតស្ថេរគង់វង្សជាអមតៈ។

ជាថ្មីម្តងទៀតខ្ញុំបាទ និងភរិយា ព្រមទាំងថ្នាក់ដឹកនាំ មន្ត្រីរាជការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខ្ញុំសូមលំអោនកាយឧទ្ទិសបួងសួងដល់វិញ្ញាណក្ខន្ធ **ឯកឧត្តម សាយ ភូថង** សូមបានចាប់បដិសន្ធិក្នុងសុគតិភពគ្រប់ៗជាតិ កុំបីឃ្លៀងឃ្លាតឡើយ។

សូម ក្រុមគ្រួសារនៃសពទាំងអស់ មេត្តាទទួលនូវមនោសញ្ចេតនាស្រឡាញ់រាប់អានដ៏ស្មោះពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦
រដ្ឋមន្ត្រី

អ៊ុត សំអេង